00644407

E9/4/4

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 15 / 02 / 2011
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (ឧបសម្ព័ន្ធជាឯកសារសម្ងាត់)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឡើង

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តីរបស់លោកនួន ជា**

លោក សុន អរុណ

Michiel PESTMAN

Victor KOPPE

Andrew IANUZZI

Jasper PAUW

PRUM Phalla

Göran SLUITER

Annebrecht VOSSENBERG (កម្មសិក្សាការីច្បាប់)

<u>ផ្ញើជូន</u>៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន៨០ (២) នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធាន") និងដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ("ដីកាបង្គាប់ស្តីពីការរៀបចំ សវនាការ")[1] ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា (ក្រុមមេធាវីការពារក្តី) សូមដាក់បញ្ជីឈ្មោះរបស់សាក្សី[2] អ្នកជំនាញ[3] និងដើមបណ្តឹងរដ្ឋប្បវេណី[4] (ជារួម "បញ្ជីសាក្សីដាក់ដោយក្រុមមេធាវីការពារក្តី")។ កាលពីថ្ងៃច័ន្ទ ទី៣១ ខែមករា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី បានទទួលបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដាក់ដោយ "សហព្រះរាជអាជ្ញា" អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង ("បញ្ជីឈ្មោះសាក្សីរបស់ក.ស.ព")[5]។ យោងតាមពេលវេលាកំណត់[6] រយៈពេល១៥ថ្ងៃ ដូចមានចែងក្នុងវិធាន៨០(២) បញ្ជីដែលបានរៀបចំបន្ទាន់ ត្រូវបានដាក់ជូនទាន់ពេលវេលា។ លើសពីនេះទៀត ក្រុមមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានខាងក្រោមទាក់ទងនឹងដីកាបង្គាប់ស្តីពីការរៀបចំសវនាការ បញ្ជីឈ្មោះសាក្សីរបស់ក.ស.ព និងបញ្ហាទាក់ទងមួយចំនួនទៀតដូចខាងក្រោម៖

## II. សារណា

---

[1] វិធាន ឯកសារ E-9 "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ", ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ERN 00635754–00635759 កថាខណ្ឌ១-៤។

[2] ត្រូវបានភ្ជាប់ទីនេះជា ឧបសម្ព័ន្ធ ក។

[3] ត្រូវបានភ្ជាប់ទីនេះជា ឧបសម្ព័ន្ធ ខ។

[4] ត្រូវបានភ្ជាប់ទីនេះជា ឧបសម្ព័ន្ធ គ។

[5] ឯកសារ E-9/4 "បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥" ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ERN 00640669–00640676។

[6] វិធាន៨០(២) ចែងថា៖ "នៅពេលដែលជនជាប់ចោទ [...] មានបំណងកោះហៅសាក្សីណាម្នាក់ ដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែល ផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា [គាត់] ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែម រួមទាំងកំណត់ហេតុនៃសាច់ញាត ដោយយោងទៅវិធាន២៤(២) ដល់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះ សាក្សី។"

## ក.ការកត់សម្គាល់ទូទៅ និងការបដិសេធ

២. ជាការចាប់ផ្ដើម វាចាំបាច់ត្រូវគូសបញ្ជាក់ថា ដោយសារឯកសារក្នុងសំណុំរឿងមានចំនួនច្រើន និងការបកប្រែឯកសារជាភាសាអង់គ្លេស និងភាសាខ្មែរដែលអាចក្លាយជាភស្តុតាង មិនទាន់រួចរាល់នៅឡើយ ដូច្នេះហើយក្រុមមេធាវីការពារក្តី មិនទាន់អាចពិនិត្យមើលសំណុំរឿងទាំងមូល និងមិនទាន់អាចពិភាក្សាព័ត៌មានទាក់ទងមួយចំនួនជាមួយលោក នួន ជា (ដែលសម្បទារបស់គាត់ក្នុងការចូលរួមដោយប្រសិទ្ធិភាពក្នុងដំណើរការនិតីវិធីទាំងនេះ នៅតែជាបញ្ហាចោទនៅឡើយ)[7]។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីរក្សាសិទ្ធិ ដាក់បន្ថែម និង/ឬ កែប្រែឯកសារទាំងនេះ *គ្រប់ពេល* តាមការណែនាំបន្ថែមពីជនជាប់ចោទ។

៣. លើសពីនេះទៀត ក្រុមមេធាវីការពារក្តីបានដាក់ការជំទាស់ជាទូទៅមួយទាក់ទងនឹងនីត្យានុកូលភាពនៃវិធានផ្ទៃក្នុង[8]។ ទោះជាការជំទាស់នោះមិនទាក់ទងជាក់លាក់នឹងការអនុវត្តវិធាន៨០ (២) ក៏ដោយ ក្រុមមេធាវីការពារក្តីមិនយល់ស្របនឹងផ្នែកខ្លះនៃដីកាបង្គាប់ស្តីពីការរៀបចំសវនាការនេះទេ ហើយស្នើឱ្យព្យួរអានុភាពនៃដីកានោះរហូតដល់មានសេចក្តីសម្រេចអំពីការជំទាស់នោះ។ ទាក់ទងនឹងបញ្ហានេះ ក្រុមមេធាវីការពារក្តីរក្សាសិទ្ធិបន្តធ្វើការជំទាស់នឹងវិធានណាដែលឃ្លាតចេញដោយខុសច្បាប់ពីនិតីវិធីកម្ពុជាដែលមានជាធរមាន។

៤. ក្រុមមេធាវីការពារក្តីមានបំណងដាក់សំណើបន្ថែមឱ្យបំពេញកិច្ចស៊ើបសួរមុនពេលធ្វើសវនាការបឋម[9]។

## ខ. ភាសា និងការបកប្រែ

៥. ដូចមានចែងក្នុងមាត្រាទី២.២ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅ អ.វ.ត.ក ក្រុមមេធាវីការពារក្តីសូមជូនដំណឹងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងថា ខ្លួនមានបំណងដាក់ និងទទួល

---

[7] *សូមមើល* ឯកសារ E-30 “សំណើជាបន្ទាន់សុំចាត់តាំងអ្នកជំនាញផ្នែកសម្បទា” ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00641421–00641436។

[8] *សូមមើល* E-42 ‘អញ្ញត្រកម្មទាក់ទងនឹងនីត្យានុកូលភាពនៃវិធានផ្ទៃក្នុង និងអានុភាពនៃដីការបស់អង្គជំនុំជម្រះសាលដំបូង ចេញនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១’ ERN 00643756-00643767។

[9] *សូមមើល* វិធាន៩៣(១) (“ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា”)

ឯកសារជាភាសាអង់គ្លេស និងភាសាខ្មែរ[10]។ ដោយសារក្រុមមេធាវីការពារក្តីមិនមានសមត្ថភាពផ្នែកភាសាបារាំង ក្រុមមេធាវីការពារក្តីមិនអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារបកប្រែជាភាសាបារាំងពីភាសាអង់គ្លេសដែលជានិង/ឬពីភាសាខ្មែរឡើយ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីមិនមានបំណងដាក់ឯកសារជាភាសានោះឡើយ។ លើសពីនេះ ដោយសារឧបសគ្គដែលមាននៅពេលបច្ចុប្បន្ន (និងឧបសគ្គកំពុងប្រឈម)របស់ អង្គភាពបកប្រែភាសា ក្រុមមេធាវីការពារក្តីមិនអាចផ្តល់ឯកសារបកប្រែនៃឧបសម្ព័ន្ធភ្ជាប់នៅពេលនេះទេ[11]។ ឯកសារបកប្រែនៃឯកសារទាំងនេះមិនទាន់មាននៅឡើយទេ ហើយឯកសារជាភាសាខ្មែរនឹងត្រូវ ដាក់ឱ្យឆាប់បំផុតតាមតែអាចធ្វើបាន។

## គ. ព័ត៌មានទាក់ទងនឹងសាក្សីនីមួយៗដែលត្រូវបានស្នើឡើង

៦. ក្រុមមេធាវីការពារក្តីបានខិតខំព្យាយាមដាក់ឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើនៅក្នុងកថាខណ្ឌ២ ក្នុងដីកាបង្គាប់ស្តីពីការរៀបចំសវនការ តាមលទ្ធភាពដែលអាចធ្វើបាន។ ទោះបីយ៉ាងណាក៏ដោយ ដូចមេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ បានធ្វើការកត់សម្គាល់[12] ក្រុមមេធាវីការពារក្តីយល់ឃើញថា ខ្លួនជាប់កាតព្វកិច្ចគោរពតាមការហាមឃាត់មិនឱ្យបំពេញកិច្ចការស៊ើបអង្កេតដោយខ្លួនឯង ដូច ក.ស.ច.ស បានប្រកាស នៅពេលចាប់ផ្តើមដំណើរការនីតិវិធីនេះថា៖

> នៅចំពោះមុខយុត្តាធិការនេះ អំណាចក្នុងការស៊ើបអង្កេតត្រូវប្រគល់ឱ្យតែសហចៅក្រមស៊ើបអង្កេតឯករាជ្យពីររូបតែប៉ុណ្ណោះ ហើយមិនឱ្យទៅភាគីឡើយ។ មិនមានបទប្បញ្ញត្តិណាមួយដែលអនុញ្ញាតឱ្យភាគីបំពេញ

[10] *សូមមើល* សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៥ (មាត្រា២.២ ចែងថា: "បុគ្គលដែលមានសិទ្ធិដាក់ឯកសារនៅ អ.វ.ត.ក ត្រូវជូនដំណឹងទៅក្រឡាបញ្ជីដែលពាក់ព័ន្ធអំពីភាសាជាផ្លូវការរបស់ អ.វ.ត.ក បន្ថែមលើភាសាខ្មែរដែលចង់ឱ្យប្រើប្រាស់សំរាប់ដាក់ឯកសារ និងឯកសារដែលត្រូវទទួលមកវិញ។")

[11] *កំណត់សម្គាល់ពិសេស* ប្រសិនបើចាំបាច់ ក្រុមមេធាវីការពារក្តី អាចផ្តល់ជូននូវលិខិតទំនាក់ទំនងជាមួយអង្គភាពបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ និងអ្នកបកប្រែរបស់អង្គភាពគាំពារការពារក្តីបាន។

[12] សូមមើល ឯកសារ E-9/1 "សំណើរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ERN 00637123–00637125 កថាខណ្ឌ៤-៥។

កិច្ចការស៊ើបអង្កេត ជំនួសសហចៅក្រមស៊ើបអង្កេត ដូចករណីនៅក្នុងប្រព័ន្ធនីតិវិធីផ្សេងទៀតនោះទេ[13]។

ដោយមិនមានបំណងជំទាស់នឹង "បទប្បញ្ញត្តិក្នុងវិធាន៣៥ និង៣៨" នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក[14]" ឬនីតិវិធីជាក់លាក់របស់កម្ពុជាទាក់ទិននឹងការ "ការបង្ខិតបង្ខំសាក្សី[15]" ក្រុមមេធាវីការពារក្តីគោរពតាមយ៉ាងខ្ជាប់ខ្ជួនចំពោះសេចក្តីណែនាំរបស់សហចៅក្រមស៊ើបអង្កេត។

៧. ទាក់ទងនឹងបញ្ហានេះ ព័ត៌មានដែលត្រូវបានស្នើជាច្រើន មិនត្រូវបានផ្តល់ឱ្យ ឬត្រូវបានផ្តល់ឱ្យតែមួយផ្នែកប៉ុណ្ណោះ[16]។ ទោះបីជាយ៉ាងណា ឈ្មោះពេញ (និងព័ត៌មានដទៃដែលអាចរកបាន) របស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ត្រូវបានដាក់ជូន រួចហើយ[17]។ ក្រុមមេធាវីការពារក្តីយល់ឃើញថា ការផ្តល់ព័ត៌មានទាំងនេះស្របគ្នានឹងកាតព្វកិច្ចដែលមានចែងក្នុងច្បាប់កម្ពុជា[18] និងការបកស្រាយពេលថ្មីៗនេះរបស់អង្គបុរេជំនុំជម្រះអំពីដីកាបង្គាប់ស្តីពីការរៀបចំសវនាការ[19]។ មេធាវីការពារក្តីនឹងដាក់បញ្ចូលការប៉ាន់ប្រមាណពេលវេលាចំពោះ

---

[13] ឯកសារ A-110/I អនុស្សរណៈរបស់ ក.ស.ច.ស ឆ្លើយតបទៅនឹងលិខិតរបស់ លោក សុន អរុណ និងលោក Michiel Pestman ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ERN 00157729–00157729 កថាខណ្ឌ៣។

[14] *ដូចជើងទំព័រខាងលើ*។

[15] *ដូចជើងទំព័រខាងលើ*។

[16] *សូមមើល ឧទាហរណ៍* ឯកសារ E-9/1 សំណើរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ERN 00637123–00637125 កថាខណ្ឌ៦ (ដោយហេតុថាសេចក្តីសម្រេចអំពីវិធានការការពារត្រូវបានគេដាក់ជាផ្នែក "សម្ងាត់បំផុត" នៃសំណុំរឿង ហើយដែលមេធាវីការពារក្តីមិនអាចទទួលបានព័ត៌មានទាំងនេះបានទេ។ មេធាវីការពារក្តីមិនមានសិទ្ធិដើម្បីផ្តល់ព័ត៌មាន។

[17] សម្គាល់ ប្រសិនបើព័ត៌មានទាំងនេះអាចរកបាន មេធាវីការពារក្តី មេធាវីការពារក្តីបានស្វែងរកដើម្បីផ្តល់ឈ្មោះពេញ ភេទ ថ្ងៃខែឆ្នាំកំណើត និងព័ត៌មានសម្រាប់ទំនាក់ទំនងសម្រាប់សាក្សី និងអ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើ។ ចំពោះបុគ្គលដែលមានព័ត៌មានតិចតួចដែលអាចរកបាន មេធាវីការពារក្តីបានព្យាយាមផ្តល់ព័ត៌មានទាំងអស់ដែលខ្លួនរកបាននៅពេលដាក់ឯកសារដើម្បីជួយសម្រួលដល់ អជសដ ក្នុងការរកអ្នកទាំងនោះ។

[18] *សូមមើល* លេខ១០ *កថាខណ្ឌខាងលើ*។

[19] *សូមមើល* ឯកសារ E9/1/1 អនុស្សរណៈអន្តរការិយាល័យពីអង្គបុរេជំនុំជម្រះសាលាដំបូងជូនចំពោះគ្រប់ភាគីទាំងអស់នៃសំណុំរឿង០០២ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ERN 000641351 ("អង្គជំនុំសាលាដំបូងសូមបញ្ជាក់ថា ឧបសម្ព័ន្ធ២ នៃដីការ

សក្ខីកម្មត្រូវបានស្នើឡើងជាមួយនឹងសេចក្ដីសង្ខេបលើសាក្សី។

## ឃ. សាក្សីបន្ថែម

៨. ក.ស.ព បានបញ្ជាក់ថាខ្លួនមិនបានដាក់ឈ្មោះបុគ្គលមួយចំនួននៅក្នុងបញ្ជីរបស់ខ្លួនទេ "ដោយផ្អែកលើមូលដ្ឋានថា សហព្រះរាជអាជ្ញានឹងត្រូវទទួលបានការអនុញ្ញាតឲ្យបញ្ចូលជាភស្តុតាងនូវចម្លើយរបស់សាក្សីនានា ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗអនុលោមទៅតាមវិធាន៨៧[20]"។ ក្រុមមេធាវីការពារក្ដីសូមរក្សាសិទ្ធិស្នើកោះហៅសាក្សីជាបុគ្គលណាមួយ និងគ្រប់សាក្សីទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីដែលផ្ដល់ដោយ ក.ស.ព (ឬភាគីដទៃ) និងត្រូវបានអង្គជំនុំជម្រះទទួលយក។ លើសពីនេះទៀត ក្រុមមេធាវីការពារក្ដីសូមរក្សាសិទ្ធិស្នើកោះហៅសាក្សី*ណាមួយ* ទាក់ទងនឹងការវិវត្តនៃភស្តុតាងថ្មី ឬភស្តុតាង*ណាមួយ*ដែលមិនបានរំពឹងទុក ក្នុងពេលសវនាការ។

## ង. សាក្សីមួយចំនួនដែលកាំង ហ្កេកអ៊ាវ ផ្ដល់ឈ្មោះក្នុងកំណត់ហេតុសួរចម្លើយ ធ្វើឡើងដោយ ក.ស.ច.ស ក្នុងសំណុំរឿង00១

៩. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២00៨ ក្រុមមេធាវីការពារក្ដីបានដាក់ "សំណើសុំកិច្ចស៊ើបអង្កេតលើកទី២" ដោយបានស្នើឲ្យ ក.ស.ច.ស កំណត់អត្តសញ្ញាណ ស្វែងរកទីតាំង និងស្ដាប់ចម្លើយបុគ្គលចំនួន៩៤រូប ដែលជនត្រូវចោទឈ្មោះកាំង ហ្កេកអ៊ាវ (ហៅ "ឌុច") បានលើកឡើងក្នុងពេលសួរចម្លើយធ្វើឡើងដោយ ក.ស.ច.ស[21]។ ក្នុងករណីដែលបុគ្គលណាមួយត្រូវបានកំណត់អត្តសញ្ញាណថាបានស្លាប់ ក.ស.ច.ស ត្រូវបានស្នើឲ្យ"ផ្ដល់ភស្តុតាងពីការស្លាប់នោះ"[22]។ ជាការអនុវត្តសំណើនេះ ក.ស.ច.ស បានផ្ដល់បញ្ជីឈ្មោះបុគ្គលដែលត្រូវបានអះអាងថាមានភស្តុតាងបង្ហាញថាបានស្លាប់។ នៅក្នុងបណ្ដឹងឧទ្ធរណ៍ចំពោះអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ក្រុមមេធាវីការពារក្ដីបានយល់ថាភស្តុតាងដែលបានលើកឡើងនោះ មិនមានភាពគ្រប់គ្រាន់ទេ[23]។ ទោះបីយ៉ាងណា

---

របស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យដាក់សម្ភារៈតម្រូវឲ្យភាគីដាក់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ ដែលភាគីអាចស្វែងរកបាន។ ប្រការនេះនឹងពាក់ព័ន្ធជាសំខាន់ទៅដល់សាក្សីនានា ដែលភាគីខ្លួនឯងបានស្នើមកអង្គជំនុំជម្រះសាលាដំបូងជាលើកដំបូង")។

[20] បញ្ជីឈ្មោះសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា កថាខណ្ឌ១0។

[21] សូមមើលឯកសារ D-100 " សំណើសុំឲ្យស៊ើបអង្កេតលើកទីពីរ", ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២00៨ ERN 00212314–00212322

[22] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ១0។

[23] *សូមមើល* ឯកសារ D-100/9/1 "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ទៅសំណើលើកទី២ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២0១0 ERN 00439479–00439488 កថាខណ្ឌ២-១៣។

អង្គបុរេជំនុំជម្រះបានគាំទ្រដីកាសម្រេចរបស់ ក.ស.ច.ស[24]។ នៅដំណាក់កាលនៃដំណើរការនីតិវិធីនេះ ក្រុមមេធាវីការពារក្តីបញ្ជាក់ជាថ្មីម្តងទៀតនូវការជំទាស់ខាងលើ និងជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួនមិនទទួលស្គាល់យុត្តិកម្មរបស់សហចៅក្រមស៊ើបអង្កេតដែល គាំទ្រការបញ្ជាក់របស់ពួកគាត់ថាបុគ្គលដែលបានលើកឡើងទាំងនោះពិតជាទទួលមរណៈភាពមែន។ ហេតុដូច្នេះហើយ ក្រុមមេធាវីការពារក្តីយល់ឃើញថា អ្នកទាំងនោះគួរតែត្រូវផ្តល់សក្ខីកម្ម ជាសាក្សីក្នុងពេលសវនាការ ដោយមូលហេតុផលដូចគ្នាដែលបានលើកឡើងក្នុងសំណើលើកទី២[25]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធមិនព្រមអនុវត្តបែបនេះនៅក្នុងដំណាក់កាលនេះទេ ក្រុមមេធាវីការពារក្តីសូមរក្សាសិទ្ធិស្នើកោះហៅអ្នកទាំងនោះដើម្បីឆ្លើយតបនឹងការផ្តល់សក្ខីកម្មរបស់ឌុចក្នុងពេលសវនាការ។

## ច. សាក្សីរបស់ព្រះរាជអាជ្ញា

១០. អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគី "ចង្អុលបង្ហាញថាតើភាគីនីមួយៗមានបំណងជំទាស់ទៅនឹងការកោះហៅសាក្សី ឬអ្នកជំនាញណាមួយដែលត្រូវបានស្នើសុំដែរឬទេ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការជំទាស់នោះ[26]" មិនឱ្យហួសពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១" ។ ជាក់ស្តែង ក្រុមមេធាវីការពារក្តីមិនអាចធ្វើការសម្រេចចិត្ត និងផ្តល់មូលហេតុបានទេ រហូតដល់សេចក្តីសង្ខេបអំពីសាក្សី (រួចរាល់នៅថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១១[27]) ត្រូវបានដាក់ជូន និងពិនិត្យរួច។ ការផ្តល់រយៈពេល៥ថ្ងៃដើម្បីអនុវត្តតាមសេចក្តីបង្គាប់ខាងលើនេះ ពិតជាមិនសមហេតុផលឡើយ ដោយសារសាក្សីក្នុងបញ្ជីសាក្សីរបស់ ក.ស.ព[28] មានចំនួនច្រើន។ ដូច្នេះហើយ ក្រុមមេធាវីការពារក្តីនឹងព្យាយាមដាក់ការជំទាស់របស់ខ្លួនក្នុងរយៈពេលវេលាសមស្របមួយ ស្របទៅនឹងសិទ្ធិរបស់ខ្លួនក្នុងការទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំខ្លួនដើម្បីការពារក្តី។ ក្រុមមេធាវីការ

---

[24] *សូមមើល* ឯកសារ D-100/9/2 "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០ ERN 00494530–00494543។

[25] *កំណត់សម្គាល់ពិសេស* ដោយសារឈ្មោះទាំងនេះ ត្រូវបានដាក់ក្នុងបញ្ជីដាក់ដោយឡែកមួយ (*សូមមើល* ឯកសារ D-203/1.1 "ឧបសម្ព័ន្ធក តារាងសង្ខេបលទ្ធផលស៊ើបអង្កេត", ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០០៩ ERN 00375831-00375858) ក្រុមមេធាវីការពារក្តី មិនបានដាក់បញ្ចូលឈ្មោះទាំងនេះនៅក្នុងបញ្ជីសាក្សីរបស់ខ្លួនឡើយ។

[26] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ កថាខណ្ឌ៨។

[27] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ កថាខណ្ឌ៦។

[28] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ កថាខណ្ឌ៦។

ពារក្តី យល់ឃើញថា ការធ្វើដូច្នេះស្របតាមកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងក្នុងច្បាប់កម្ពុជា[29]។

## ឆ. លំដាប់លំដោយដែលបានស្នើឡើងនៃសក្ខីកម្មសាក្សី

១១. ក.ស.ព បានស្នើនូវលំដាប់លំដោយលេខរៀងរបស់សាក្សីដែលខ្លួនបានស្នើឡើងដែលក្នុងនោះសាក្សី "គួរត្រូវបានកោះហៅឱ្យមកបង្ហាញខ្លួននៅពេលធ្វើសវនាការ ដែលនៅក្នុងនោះបញ្ហាជាគន្លឹះនានា និងចំណុចនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គួរបានលើកមកបង្ហាញ[30]"។ ក្នុងដំណាក់កាលនេះ ក្រុមមេធាវីការពារក្តីបានធ្វើការកត់សម្គាល់សំណើរបស់ ក.ស.ព និងធ្វើការសន្និដ្ឋានថា បញ្ហាទាក់ទងលំដាប់លំដោយលេខរៀងសាក្សី ដែលស្ថិតក្នុងចំណោមបញ្ហាជាច្រើនទៀត គួរតែលើកយកមកពិភាក្សាឱ្យបានទូលំទូលាយនៅកិច្ចប្រជុំរៀបចំសវនការនៅពេលខាងមុខនេះ។

## ជ. ធាតុផ្សំខាងបរិបទ

១២. យោងតាម ក.ស.ព ៖ "ដើម្បីជាប្រយោជន៍នៃភាពច្បាស់លាស់ ប្រសិទ្ធភាព និងយុត្តិធម៌ [...] សាក្សីទាំងនោះ [ស្នើឡើងដោយភាគីដទៃ] នឹងត្រូវបានវាយតម្លៃតាមបញ្ហាជាគន្លឹះ និងព្រឹត្តការណ៍ឧក្រិដ្ឋកម្មនានាដែលពួកគេអាចបំភ្លឺបាន និងចូលបង្ហាញខ្លួនដើម្បីផ្តល់ចម្លើយស្របតាមបញ្ហា ឬទីតាំងចំបងដែលពួកគាត់អាចផ្តល់ភស្តុតាងបាន ដើម្បីឱ្យគ្រោងការរួមសម្រាប់ការធ្វើបទបង្ហាញនេះដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះ ត្រូវបានរក្សាទុកដដែល"[31]។ ជាការកត់សម្គាល់ មិនមានការយោងទៅនឹងពេលវេលាមុនឆ្នាំ១៩៧៥ នៅក្នុងរបៀបវារៈដែលបានលើកឡើងដោយ ក.ស.ព ទេ។ នេះបង្ហាញថា សហព្រះរាជអាជ្ញាមិនយល់ឃើញថា ភស្តុតាងបរិបទទាក់ទងទៅនឹងពេលវេលានោះមានសារៈសំខាន់ចំពោះដំណើរការនីតិវិធីឡើយ។ ទោះបីយ៉ាងណាក៏ដោយក៏ ក.ស.ព បានលើកឡើងអំពីសារៈសំខាន់នៃធាតុផ្សំបរិបទទាំងនេះដើម្បីឱ្យយល់ដឹងពេញលេញ

---

[29] *សូមមើលលេខ៩ កថាខណ្ឌខាងលើ*។

[30] បញ្ជីឈ្មោះសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា កថាខណ្ឌ១៥។

[31] បញ្ជីឈ្មោះសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា កថាខណ្ឌ២០។

អំពីបញ្ហានានានៅក្នុងសំណុំរឿងនេះ[32]។ ក្នុងការវាយតម្លៃពីភាពជាប់ទាក់ទងរបស់សាក្សីមួយចំនួន ដែលស្នើឡើងដោយក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងផ្តោតទៅលើយុត្តិសាស្ត្រអន្តរជាតិដែលបានចង្អុលបង្ហាញថា "យើងអាចពឹងផ្អែកទៅលើអំពើដែលបានកើតឡើងមុនយុត្តាធិការលើ ពេលវេលា ប្រសិនបើភស្តុតាងបញ្ជាក់អំពីបរិបទមួយនោះ" [33]។

## ឈ. ការសួរសាក្សីដោយផ្ទាល់

១៣. ក.ស.ព បានបញ្ជាក់ថា "សហព្រះរាជអាជ្ញា មិនទាន់បានទាក់ទងជាមួយអ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីទេ[34]"។ ទាក់ទងទៅនឹងការហាមឃាត់ជាទូទៅប្រឆាំងនឹងការសួរសាក្សីដោយផ្ទាល់ក្នុងដំណើរការនីតិវិធីក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងបទបញ្ញា/ច្បាប់កម្ពុជាទាក់ទងនឹងបញ្ហានេះ[35] ក្រុមមេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូង ធ្វើការរំលឹកដល់ ក.ស.ព និង ក្រុមមេធាវីរបស់ភាគីដទៃ ឱ្យបន្តកាតព្វកិច្ចរបស់ពួកគេដោយជៀសវាងធ្វើទំនាក់ទំនងច្រើនជាមួយសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី នៅពេលណាមួយមុនពេលផ្តល់សក្ខីកម្ម។

---

[32] *សូមមើល* ឯកសារ D-365 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ 00478047–00478055 កថាខណ្ឌ១។

[33] *សូមមើល* ឯកសារ No D-365/2/1 "សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលគាំទ្រការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម" ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ERN 00508881–00508908 កថាខណ្ឌ១១ (ដកស្រង់ពីឯកសារ D-300 ដីកាសម្រេចលើសំណើ D-153, D-172, D-174, D-178 និង D-284 ) ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ERN 00428047–00428058 កថាខណ្ឌ៩ (*ទាញសំអាងហេតុ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Nahimana និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-52-A សាលដីកាចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៣១៥))។

[34] បញ្ជីឈ្មោះសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា កថាខណ្ឌ៣។

[35] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣២៦។ ក្រមសីលធម៌នៃមេធាវី ដែលបានចុះក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៣(៣)។

## ៣. អ្នកជំនាញ

១៤. អនុលោមតាមដីកាឲ្យរៀបចំសវនាការ មេធាវីការពារក្ដីបានដាក់ជូននូវបញ្ជីឈ្មោះអ្នកជំនាញដែលបានស្នើ។ បន្ថែមពីលើនេះទៀត ឈ្មោះជាច្រើនដែលមានក្នុងបញ្ជីសាក្សី អាចទទួលស្គាល់ថា ជាអ្នកជំនាញបាន ហើយមេធាវីការពារក្ដីអាចសូមកោះហៅអ្នកទាំងនោះជាអ្នកជំនាញនៅពេលសវនាការ។ (ឈ្មោះគាត់ត្រូវបានបង្ហាញក្នុងអក្សរពណ៌ក្រហម និងសម្គាល់ដោយសញ្ញារូបផ្កាយក្នុងបញ្ជីសាក្សី)។ ដោយសារតែបុគ្គលទាំងនេះអាចផ្ដល់សក្ខីកម្មលើអង្គហេតុ និងដោយពិចារណាលើលក្ខណៈសម្បត្តិគតិយុត្តិរបស់គាត់ជា "អ្នកជំនាញ" អាចជាការបើកផ្លូវមួយសម្រាប់ការពិភាក្សា និងដាក់សារណាបន្ថែមទៀត មេធាវីការពារក្ដីសូមរក្សាសិទ្ធិក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញ និងបញ្ជាក់ពីឋានៈរបស់គាត់។

## III. សេចក្ដីសន្និដ្ឋាន

១៥. សេចក្ដីសន្និដ្ឋានទាំងនេះមិនទាន់គ្រប់ទាំងអស់ទេ។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពាក្ដី សូមរក្សាសិទ្ធិគ្រប់យ៉ាងដែលផ្ដល់ឲ្យលោក នួន ជា ដែលមានចែងក្នុងច្បាប់កម្ពុជា និងអន្តរជាតិច្បាប់អន្តរជាតិ។

សហមេធាវីការពារក្ដីរបស់លោកនួន ជា

លោក សុន អរុណ

Michiel PESTMAN និង Victor KOPPE